Asian Community Center 21

【Report on Tohoku Volunteer Program 2012】

Mother Tongue

Name: យ៉ែម វិបុល

## 【In your mother tongue】

1. What impression did you have on Tohoku after 1.5 year of disaster?

ការប្រឹងប្រែងរបស់ប្រជាជននៅអ៊ិស៊ិណូម៉ាគិ ពិតជាគួរអោយសរសើរក្រៃលែង។ ក្រោយការរងគ្រោះស៊ឺណាមិជាង១ឆ្នាំកន្លះ ពួកគាត់បានស្តារឡើងវិញស្ទើរតែទាំងស្រុង។ ហើយខ្ញុំក៏សែនសប្បាយចិត្ត នៅពេលឃើញពួកគាត់ មានស្នាមញញឹមឡើងវិញ។

2. Please describe your experiences and tell us your reflection of them (for example, the work which you were engaged in, people's conditions you observed, the stories you heard from them, and any other interesting experiences you would like to share with readers of this report).

ខ្ញុំបានជួយពួកគាត់ ក្រងសំបកងាវធំៗ ដើម្បីយកគ្រុមសមុទ្ទ និងជួយដេរសំណាញ់ដើម្បីចិញ្ចឹមត្រី។ វាបានបង្រៀនអោយខ្ញុំយល់ពីកិច្ចការទាំងនោះ ព្រមទាំងអោយខ្ញុំស្គាល់ពីមុខរបរចិញ្ចឹមជីវិតជាប្រចាំថ្ងៃរបស់ពួកគាត់។ ពួកគាត់បាននាំពួកយើងទៅមើលកន្លែងចិញ្ចឹមត្រី និងគ្រុមក្នុងសមុទ្ទ ព្រមទាំងបង្ហាញដីបាក់ពេលស៊ឺណាមិ។ សមុទ្ទ កោះ និងរុក្ខជាតិទាំងឡាយ បង្កើតបានជាទេសភាពដ៏ស្រស់ស្អាត ហើយអាហារសមុទ្ទ ដូចជាត្រីអាំង ស៊ុបគ្រុម ដែលពួកគាត់ធ្វើទទួលពួកខ្ញុំពិតជាមានរស់ជាតិឆ្ងាញ់។ ទាំងនេះបានទាក់ទាញចិត្តខ្ញុំអោយចង់រស់នៅទីនោះ។

ពេលលាគ្នា ខ្ញុំស្ទើរតែទប់ទឹកភ្នែកមិនបាន។ ពួកគាត់បាននិយាយថា ពួកគាត់នឹងព្យាយាមស្តារភូមិស្រុកគាត់អោយសំបូរសប្បាយឡើងវិញ ហើយបើមានឱកាស សូមទៅលេងពួកគាត់ផង។ ខ្ញុំនឹងទៅដើម្បីបង្កើនទំនាក់ទំនង និងរៀនរកគ្រុម ឬត្រីពីពួកគាត់អោយបានច្រើនជាងនេះទៀត។

3. What did you learn from Tohoku and what would you like to suggest to your country people in case of natural disasters that might happen in your country?

ក្រោយពីបានស្វែងយល់ពីគ្រោះមហន្តរាយនៅតំបន់តុហុគឺ ខ្ញុំយល់ថា ពួកយើងទាំងអស់គ្នាគួរអនុវត្តវិធីសាស្រ្តដែលមានបីដំណាក់កាលដូចតទៅ។ ទីមួយ ហ្វឹកហាត់របៀបរត់គេចពីគ្រោះថ្នាក់កុំចាំវាមកដល់។ ទីពី ពេលគ្រោះធម្មជាតិកើតឡើង ទោះតូចក៏ដោយសូមកុំគិតថាវាមិនអី តែគួររកកន្លែមានសុវត្ថភាព។ ទីបី ក្រោយគ្រោះថ្នាក់ គួរតែលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីរួមដៃគ្នាស្តារឡើងវិញ។

ជំនួយផ្នែកស្មារដី មានសារៈសំខាន់ណាស់ ចំពោះអ្នកបានបាត់បង់ទ្រព្យសម្បត្តិ ឬមនុស្សជាទីស្រលាញ់របស់ខ្លួន។ នៅកម្ពុជា គ្រោះធម្មជាតិមានរៀងរាល់ឆ្នាំ។ តែជំនួយផ្នែកស្មារតីតាមរយៈក្រុមស្ម័គចិត្តនេះ មិនសូវដែលឃើញទេ។ ហេតុដូចនេះ ខ្ញុំក៏មានបំណង ចង់បង្កើតក្រុមស្ម័គចិត្តដូចគ្នានេះដែរ។

4. Your message to your country people

បងប្អូនប្រជាជនខ្មែរជាទីរាប់អាន ទីណាក៏ដូចទីណាដែរ។ មិនថាសង្គ្រាមឬគ្រោះមហន្តរាយធម្មជាតិទេ វាតែងធ្វើអោយយើងបាត់បង់អ្វីៗគ្រប់យ៉ាង។ សំខាន់សួរថា តើយើងមានគំនិតអ្វីដើម្បីការពារ គ្រោះមហន្តរាយនោះទេ? ហើយក្រោយ គ្រោះមហន្តរាយ តើយើងមានទឹកចិត្តស្តារភូមិស្រុកយើងឡើងវិញទេ? ទាំងនេះ ក៏វាអាស្រ័យលើការលើកទឹកចិត្តនិងជួយគ្នាទៅវិញទៅមក។ ជំនួយសំភារៈឬទឹកប្រាក់ពីខាងក្រៅ វាបានតែមួយពេលទេ តែការស្តារអោយស្រុកទេសសំបូរសប្បាយ វាសំខាន់ណាស់សំរាប់តកូនតចៅយូរអង្វែង។ ក្រោយគ្រោះធម្មជាតិដ៏សាហាវនេះ ប្រជាជនជប៉ុននៅតែព្យាយាមស្តារភូមិស្រុកគាត់មិនរាថយ។ ខ្ញុំក៏ចង់ឃើញប្រជាជនយើង ពួតដៃគ្នាប្រឹងប្រែងដូចជនជាតិជប៉ុនដែរ។